ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ:** លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ:** ជំនួបពិភាក្សាការងារជាមួយ លោកជំទាវ Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសហការី ។

ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង១០:០០ នាទីព្រឹកនៅសាលប្រជុំខេត្តតាកែវ ទីស្តីការក្រសួងមហាផ្ទៃ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយ លោកជំទាវ Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសហការី ដើម្បីសិក្សា និងដកពិសោធន៍ការងារបន្ថែមអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

### I.សមាសភាពចូលរួម

**គណៈកម្មាធិការជាតិ គ.ជ.ប.ជ**

១.លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
២.ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់ណា អគ្គលេខាធិការរង គ.ជ.ប.ជ
៣.ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារ៉ុ អគ្គលេខាធិការរង គ.ជ.ប.ជ
៤.លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ
៥.ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ
៦.លោក ឧត្តមសេនីយ៍ទោ សេក ស៊ីវ៉េត ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ
៧.លោក ឧត្តមសេនីយ៍ទោ ប៉ុណ្ណ ចន្ថា ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌
៨.លោក ឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់

**ស្ថានទូតសហរដ្ឋអាមេរិក:**

១.លោកស្រី Jamie Sutter, International Program Officer
២.លោកស្រី Veronika Sutter, Staff Assistant
៣.លោក John Milicevich, U.S Embassy
៤.លោក អ៊ុំ ច័ន្ទបញ្ញារ៉ា, U.S Embassy ( អ្នកបកប្រែ )

II.ដំណើរការ នៃកិច្ចពិភាក្សា

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ចំពោះដំណើរទស្សនកិច្ចរបស់ លោកជំទាវ Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសហការី ដែលបានចំណាយពេលវេលាជួបសំណេះសំណាល ពិភាក្សាការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយថ្នាក់ដឹកនាំរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។ **លោកជំទាវ** រដ្ឋលេខាធិការ បានមានប្រសាសន៍អំពីចេតនាសម្ព័ន្ធ និងដំណើរការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចុះប្រតិបត្តិការបង្ក្រាបបទល្មើសជួញដូរមនុស្សនៅកម្ពុជា ការជួយសង្គ្រោះជនរងគ្រោះ ការផ្តន្ទាទោសជនល្មើស នៃអំពើជួញដូរមនុស្ស ហើយក៏មានបញ្ហាប្រឈមផងដែរ ដូចជា បញ្ហាប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលជនល្មើសបានប្រើប្រាស់ ដើម្បីទាក់ទាញបោកបញ្ឆោតជនរងគ្រោះ ទាំងក្នុងប្រទេស និងក្រៅប្រទេសមកចាញ់បោក រហូតក្លាយជាជនរងគ្រោះនៅកម្ពុជា ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានកិច្ចសហការពីបណ្តាអង្គការដៃគូជាតិ អន្តរជាតិមួយចំនួនសំដៅរួមគ្នាក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា បច្ចុប្បន្ននេះបានរួមគ្នាគិតគូរអំពីប្រព័ន្ធបញ្ជូនថ្នាក់ជាតិ និងរបៀបការផ្តល់សេវាទាំងខ្មែរ និងជនបរទេសធ្វើយ៉ាងណាឲ្យមានភាពល្អប្រសើរជាងមុន ។ **លោកជំទាវ** មានប្រសាសន៍បន្ថែមថា មានការផ្សព្វផ្សាយនូវព័ត៌មានមិនជាក់លាក់ ដែលបានចោទមកលើកម្ពុជាថា មានជនរងគ្រោះជាប់នៅក្នុងការងារដោយបង្ខំ នៃប្រព័ន្ធអនឡាញរហូតដល់ដប់ម៉ឺននាក់ ហើយកម្ពុជាបានខិតខំប្រតិបត្តិការស្រាវជ្រាវតាមបណ្តឹងដែលមានជាង ១២០០សំណើ ប៉ុន្តែរកមិនឃើញអ្នកដែលជាប់នៅតាមទីតាំងដែលប្រព្រឹត្តបទល្មើសរាប់ម៉ឺននាក់នោះទេ ហេតុនេះទើបកម្ពុជាតែងតែប្រតិកម្មទៅនឹងព័ត៌មានដែលមិនជាក់លាក់ មិនមានភ័ស្តុតាងច្បាស់លាស់ដែលបានធ្វើការផ្សព្វផ្សាយ ពីព្រោះនេះ គឺមានការប៉ះពាល់ដល់កិត្តិយសមុខមាត់សេចក្តីថ្លៃថ្នូរ និងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ។ ទទួលស្គាល់ថាពិតជាកើតមាននូវបទល្មើសទាំងអស់នោះមែន ហើយយើងក៏បានខិតខំប្រឹងប្រែងបោសសម្អាត គឺមិនទុកឲ្យបទល្មើសទាំងនោះកើតមាននៅកម្ពុជាទេ ហើយក៏បានសហការជូនព័ត៌មានទៅបណ្តាប្រទេសពាក់ព័ន្ធដើម្បីផ្តល់កិច្ចសហការ ពីព្រោះជនល្មើសដែលយើងបានរកឃើញក៏មានជនជាតិ នៃប្រទេសទាំងនោះដែរ និងសូមថ្លែងអំណរគុណដល់ប្រទេសមួយចំនួនដែលបានផ្តល់កិច្ចសហការក្នុងការដោះស្រាយបញ្ហារួម ពីព្រោះគាត់គិតថាបទល្មើសនេះក៏បានប៉ះពាល់ និងកើតឡើងដោយជនជាតិ នៃប្រទេសគាត់ដែរ ហើយប្រទេសកម្ពុជាក៏ប៉ះពាល់ដោយសារពួកគាត់បានយកធ្វើជាទីតាំង នៃការប្រព្រឹត្តបទល្មើសផងដែរ ។ នៅក្នុងប្រតិបត្តិការនេះ ក៏ជាបទពិសោធន៍មួយដែលត្រូវរៀនសូត្របន្តទៀត ពីព្រោះ ទី១. បណ្តាញជនល្មើស គឺបានពង្រាយនៅតាមបណ្តាប្រទេសក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក រួមទាំងកម្ពុជាផងដែរ ទី២.ច្បាប់ដែលយើងបានអនុវត្តកន្លងមកតាមពិធីសារប៉ាឡឺម៉ូ ដែលបានអនុវត្តលើអំពើជួញដូរមនុស្ស គឺមិនទាន់គ្របដណ្តប់លើបទល្មើសតាមប្រព័ន្ធអនឡាញទេ ចាំបាច់ត្រូវពិភាក្សាកំណត់ថាតើនិយមន័យ នៃអំពើជួញដូរមនុស្ស បានគ្របដណ្តប់លើអ្វីខ្លះ? ចំពោះច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលបានប្រើប្រាស់ ក៏នៅមិនទាន់បានគ្រប់ដណ្តប់១០០% ទៅលើអ្វីដែលយើងបានធ្វើ ដូចជាករណីជនបរទេសដែលយើងបានសង្គ្រោះចេញពីកន្លែងដែលមិនមានសុវត្ថិភាព ហើយបានអនុវត្តទៅតាមបទដ្ឋានច្បាប់របស់យើង និងបានធ្វើការវាយតម្លៃ ឬកំណត់អត្តសញ្ញាណភាពរងគ្រោះរបស់គាត់ បើរកមិនឃើញថាគាត់មិនមែនរងគ្រោះទេ ហើយមានបំណងចង់ត្រឡប់ទៅវិញដោយគ្មានឯកសារច្បាស់លាស់ ពីព្រោះគាត់ជាជនទេសន្តរប្រវេសន៍ខុសច្បាប់ គឺកម្ពុជាមានគោលការណ៍ធ្វើរបាយការណ៍បញ្ជូនទៅប្រទេសគាត់វិញ ។ **លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះ លោកជំទាវ Cindy Dyer

និងក្រុមការងារទាំងអស់ និងសង្ឃឹមថាដំណើរទស្សនកិច្ចរបស់ លោកជំទាវ នៅប្រទេសកម្ពុជានាពេលនេះនឹងរកឃើញអ្វីដែលជាការពិតនូវកិច្ចខិតខំប្រឹងប្រែងលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាល និងផ្តល់នូវអនុសាសន៍ល្អៗក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែល្អប្រសើរ ។

**លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ថ្លែងអំណរគុណចំពោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលបានធ្វើសេចក្តីរាយការណ៍ដ៏លម្អិត អំពីសកម្មភាពថ្មីៗរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឲ្យមានការច្បាស់លាស់បន្ថែមទៀត សូមលើកជាសំណួរទៅកាន់លោកជំទាវ រដ្ឋលេខាធិការមួយចំនួនដើម្បីជួបប្រជុំ និងកិច្ចសហការលើកក្រោយ ។ **សំណួរទី១**.ពាក់ព័ន្ធការកំណត់អត្តសញ្ញាណជនរងគ្រោះ ដូចដែលទទួលបានសេចក្តីរាយការណ៍ពី លោកជំទាវថា គណៈកម្មាធិការជាតិ កំពុងតែរៀបចំកែសម្រួលបទដ្ឋាន នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ តើផ្នែកណា នាយកដ្ឋានណា ឬក្រសួងណា ដែលមានសិទ្ធិគ្រប់គ្រង អនុវត្តផ្ទាល់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ? សូមបញ្ជាក់ទាក់ទងនឹងបុគ្គលដែលត្រូវបានជួយសង្គ្រោះពីតំបន់ជាប់ពាក់ព័ន្ធនឹងអនឡាញ cyber Scam ក៏ដូចជាជនផ្សេងទៀតដែលត្រូវបានជួយសង្គ្រោះពីទីតាំងផ្សេងៗដែរ ។

**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ឆ្លើយតបទៅនឹងសំណួររបស់លោកជំទាវ Cindy Dyer ដែលបានលើកឡើងអំពីអ្នកពាក់ព័ន្ធសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាចំណែកមួយ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយត្រូវបានទទួលស្គាល់ដោយអន្តរក្រសួង ស្ថាប័ន យើងបានធ្វើការពិភាក្សា និងបានរួមគ្នារកធាតុចូលសំខាន់ៗពីដៃគូពាក់ព័ន្ធ ដើម្បីធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ រហូតសម្រេចបាននៅក្នុងឆ្នាំ២០១៥ បច្ចុប្បន្នយើងកំពុងធ្វើការកែសម្រួលដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ជាអ្នកដឹកនាំដោយសហការជាមួយគណៈកម្មាធិការជាតិជាអ្នកសម្របសម្រួល និងមានការចូលរួមពីដៃគូផងដែរ ។ អ្នកដែលមានសិទ្ធិក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជានគរបាលយុត្តិធម៌ សំដៅលើមន្ត្រីនគរបាលជំនាញថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំពោះអ្នកបង្រ្កាប គឺជានគរបាលសន្តិសុខដែលធ្វើឡើងរួមគ្នារបស់ក្រុមប្រតិបត្តិការចម្រុះ ដែលកន្លងមកយើងធ្វើសម្រាប់ផ្តល់សេវាដល់ជនរងគ្រោះ មុនពេលគាត់ទទួលបានការវាយតម្លៃចុងក្រោយពីតុលាការ ។

**លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក បន្តថា ជនរងគ្រោះដែលបានជួយសង្គ្រោះពីកន្លែង Cyber Scam គឺពួកគាត់តែងតែចង់ត្រឡប់ទៅផ្ទះវិញ ប៉ុន្តែកន្លងមកធ្លាប់ទទួលបានព័ត៌មានពីជនរងគ្រោះថា បើពួកគាត់មិនត្រឡប់ទៅផ្ទះទេ គឺពួកគាត់នឹងត្រូវបាននគរបាលដាក់បទចោទលើគាត់ តើលោកជំទាវ ធ្លាប់ទទួលបានព័ត៌មាននេះដែរទេ?

**លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ មានប្រសាសន៍បញ្ជាក់ឆ្លើយតបសំណួរថា អ្នកដែលបានសង្គ្រោះមកហើយយើងបានជួបបឋមចម្លើយរបស់គាត់មិនសូវមានការពិតទេ ពួកគាត់តែងតែរកវិធីចាកចេញពីកន្លែងនោះ និងធ្វើយ៉ាងណាដើម្បីបានទៅដល់ផ្ទះ ហើយក៏មានមួយចំនួនមិនចង់ទៅផ្ទះទេ ប៉ុន្តែពួកគាត់ចង់ត្រឡប់ទៅធ្វើការកន្លែងនោះវិញដោយសារនៅទីនោះគាត់ទទួលបានប្រាក់ខែច្រើន គាត់មិនមានភាពរងគ្រោះទេ ពេលនោះយើងបានហាមឃាត់ ពីព្រោះកន្លែងនោះកំពុងត្រូវបានស្រាវជ្រាវថាជាកន្លែងប្រព្រឹត្តបទល្មើស បើគាត់ត្រឡប់ទៅវិញគាត់អាចក្លាយជាជនរងគ្រោះ ឬជាជនរងគ្រោះដោយខ្លួនឯង ។

**លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក មានប្រសាសន៍ថា លោកជំទាវ ធ្លាប់បានជួបប្រជុំជាមួយផ្នែកប្រទេសថៃ ឡាវ និងប្រជុំតាមអនឡាញជាមួយប្រទេសហ្វីលីពីន គឺទទួលបានព័ត៌មានស្រដៀងនឹងអ្វីដែល លោកជំទាវ បានលើកឡើងនេះផងដែរ ដែលថាមានជនមួយចំនួនចង់ធ្វើការនៅកន្លែងនោះវិញដោយសារគាត់ទទួលបានប្រាក់ខែខ្ពស់ ទន្ទឹមគ្នានេះដែរ ក៏មានក្ដីបារម្ភមួយចំនួនចំពោះជនទេសន្តរប្រវេសន៍ធ្វើចំណាកស្រុក ពាក់ព័ន្ធស្ថានភាពពួកគាត់អាចក្លាយជាជនរងគ្រោះ ឬត្រូវបានបង្ខំឲ្យធ្វើការនៅកន្លែងនោះផងដែរ ។ ពាក់ព័ន្ធការដាក់ពួកគាត់ឃុំឃាំងនៅកន្លែងទេសន្តប្រវេសន៍ អាចជាចំណុចមួយដែលពិបាក មិនសូវល្អទេក្នុងគោលបំណងបញ្ជូនពួកគាត់ត្រឡប់ទៅវិញ ។

**លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ បើយើងមើលទៅគិតថាឃុំឃាំង គឺឃុំឃាំង បើយើងគិតថាជាការប្រមូលពួកគាត់ដើម្បីដោះស្រាយបញ្ហាឯកសារ ក៏ដូចជាត្រៀមចាំទទួលយកឯកសារត្រឡប់ទៅវិញ តើដាក់ពួកគាត់នៅកន្លែងណា? យើងធ្លាប់បានជួយសង្គ្រោះជនរងគ្រោះជាច្រើននាក់ក្នុងពេលតែមួយ ពេលនោះទីតាំងនៅកន្លែងអន្តោប្រវេសន៍ចង្អៀត ក៏បានយកពួកគាត់ទៅដាក់នៅកន្លែងមួយទៀតដែលទូលាយ ប៉ុន្តែគឺមានការទាក់ទងទៅនឹងជនល្មើសបានងាយស្រួល ដែលមាននគរបាលនៅចាំការពារ យើងក៏បានសាកសួរទៅពួកគាត់ថា ស្នាក់នៅកន្លែងនេះតើមានអារម្មណ៍យ៉ាងដូចម្តេច? ពួកគាត់ឆ្លើយតបថា មានអារម្មណ៍ទទួលបានសុវត្ថិភាពពីព្រោះមាននគរបាលចាំការពារ ប្រសើរជាងនៅកន្លែងផ្សេងដោយមិនមានសុវត្ថិភាព ហើយជនល្មើសមកទាក់ទងគាត់ ។

**លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក បានលើកឡើងថា នេះគឺជាការពិភាក្សាកុំឲ្យមានការភាន់ច្រឡំណាមួយ ដែលកន្លងមកធ្លាប់មានកិច្ចពិភាក្សាជាមួយបណ្តាប្រទេសមួយចំនួន ហើយប្រទេសទាំងនោះក៏មានស្ថានភាពដូចគ្នានឹងប្រទេសកម្ពុជាដែរ មិនមែនតែកម្ពុជាតែមួយទេដែលជួបបញ្ហាស្ថានភាពជួញដូរមនុស្សនេះ ។ ចំពោះអ្វីដែលយើងទទួលបានតាមរយៈការអង្កេតពិនិត្យ គឺជនរងគ្រោះទាំងអស់ត្រូវបានអូសទាញឲ្យចូលមកធ្វើការដោយការបន្លំ បោកប្រាស់ ឬត្រូវបានបង្ខំឲ្យមកធ្វើការងារទាំងអស់នេះ បើសិនយើងពិនិត្យទៅលើពិធីការ Protocol ពួកគាត់ត្រូវបានចាត់ទុកថាជាជនរងគ្រោះ ដោយមិនគិតលើស្ថានភាពទេសន្តប្រវេសន៍របស់គាត់ទេ ។ សំណួរមួយទៀត ពាក់ព័ន្ធកិច្ចខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាក់ទងនឹងការចុះបង្ក្រាបបានបទល្មើសដែលមានសញ្ជាតិផ្សេងៗគ្នា តើអាជ្ញាធរ ឬសមត្ថកិច្ចមានការចុះស៊ើបអង្កេត ឬឈានដល់ការចាប់ខ្លួនម្ចាស់អាជីវកម្ម ឬម្ចាស់ទីតាំងទាំងអស់នោះ ឬក៏មានមន្ត្រីជាន់ខ្ពស់ណាមួយមានការជាប់ពាក់ព័ន្ធ និងនៅខាងក្រោយបទល្មើសទាំងអស់នេះទេ?

**លោកជំទាវ** អនុប្រធានងចិន្ត្រៃយ៍ មានប្រសាសន៍ឆ្លើយតបថា មិនមែនជាលើកទីមួយទេដែលមានការចោទប្រកាន់លើការជាប់ពាក់ព័ន្ធអំពើពុករលួយ ឬការឃុបឃិតពីសមត្ថកិច្ច មន្ត្រីជាន់ខ្ពស់នោះ ចំពោះការបង្ក្រាបដែលយើងឃាត់ខ្លួនមិនមានតែជនបរទេសទេ ជនជាតិខ្មែរក៏មានដែរ ហើយបានបញ្ជូនទៅតុលាការ និងបន្តនីតិវិធីស៊ើបអង្កេតដើម្បីរកឲ្យឃើញការពិត សូមបញ្ជាក់ថា អ្នកប្រព្រឹត្តបទល្មើសភាគច្រើនជាជនបរទេស ដោយធ្វើការទំនាក់ទំនងនៅក្រៅប្រទេសទើបអាចនាំមនុស្សចូលមកកម្ពុជាបាន ដូច្នេះទើបឲ្យគ្រប់ប្រទេសទាំងអស់ត្រូវសហការគ្នាដើម្បីស្វែងរកមេខ្លោង បើយើងធ្វើការចោទប្រកាន់លើទីតាំង យើងអាចនិយាយបានថាទីតាំងជាធម្មតាទីតាំងដែលបានជួល គឺមានកិច្ចសន្យា ហើយក្នុងកិច្ចសន្យានឹងមិនមានការអនុញ្ញាតឲ្យប្រព្រឹត្តបទល្មើសទេ ហេតុដូចនេះការចាប់ឃាត់ខ្លួនអ្នកណាម្នាក់ គឺមិនអាចធ្វើដោយមិនមានឯកសារ ឬភ័ស្តុតាងគ្រប់គ្រាន់ទេ ហើយបណ្តាញជនល្មើសក៏គេចេះច្បាប់ដែរ និងមានការប្រើប្រាស់បច្ចេកទេសខ្ពស់ ដែលអាចធ្វើឲ្យពួកគេដឹងពីស្ថានការមុនដើម្បីត្រៀមខ្លួន ដែលជាហេតុការលំបាករបស់សមត្ថកិច្ចក្នុងការស្វែងរកបទល្មើសផងដែរ ប៉ុន្តែយើងនៅតែបន្តសកម្មភាព

ប្រតិបត្តិការបង្ក្រាប បើយើងបណ្តែតបណ្តោយនឹងធ្វើឲ្យសង្គមកាន់តែប្រឈមជាមួយបញ្ហា ដូច្នេះហើយទើបកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបង្ក្រាបអំពើជួញដូរមនុស្សនៅក្នុងប្រទេសឲ្យបានល្អប្រសើរ ។

**III.មតិបូកសរុប**

**លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក សូមថ្លែងអំណរគុណសម្រាប់ព័ត៌មានរបស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** យើងនឹងព្យាយាមឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ជួញដូរមនុស្ស ទាក់ទងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាការកំណត់អត្តសញ្ញាណជនរងគ្រោះ ការផ្តល់សេវាជូនជនរងគ្រោះផងដែរ ។ **លោកជំទាវ** បន្តថា ជោគជ័យទាំងអស់នេះ កើតឡើងដោយសារភាពជាអ្នកដឹកនាំរបស់ លោកជំទាវ និងសហការី ដែលបានចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសូមថ្លែងអំណរគុណ សម្រាប់ការចំណាយពេលវេលារបស់ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជួបពិភាក្សាការងារនាថ្ងៃនេះផងដែរ ។

**លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ មានប្រសាសន៍ថ្លែងអំណរគុណ **លោកជំទាវ** Cindy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់សហរដ្ឋអាម៉េរិក និងសហការី ដែលឆ្លៀតឱកាសជួបជាមួយក្រុមការងារប្រទេសកម្ពុជា ដើម្បីស្វែងរកការពិត អ្វីដែលបានលើកឡើងក្នុងថ្ងៃនេះ គ្រាន់តែជាជ្រុងមួយ នៃការងាររបស់យើងខ្ញុំតែប៉ុណ្ណោះ ចំពោះព័ត៌មានទាំងអស់ក្រុមការងាររបស់ លោកជំទាវ នឹងទទួលបានពីក្រុមការងារជំនាញបន្ថែមទៀត ។ ពីព្រោះនៅកម្ពុជា ធ្វើការងារជាលក្ខណៈអន្តរក្រសួង ស្ថាប័ន និងមានអង្គការដៃគូចូលរួមផងដែរ យើងនឹងរួមគ្នាទទួលខុសត្រូវប្រកបដោយឆន្ទៈខ្ពស់ ហើយសង្ឃឹមថាក្រុមការងារវាយតម្លៃរបស់សហរដ្ឋអាម៉េរិក នឹងពិនិត្យ ពិចារណាឡើងវិញ អំពីចំណាត់ថ្នាក់លេខ៣ ដែលមានពីរឆ្នាំនេះ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក សោ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ៨ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ
20/11/23

ជូ ម៉ិនអេង